**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*****

ឌី.ប៊ី.ឌី អ៊ិនជីនារីង ម.ក
DBD Engineering Plc.

លេខ: ១៨៧/២២ ឧបឌ

**សេចក្តីជូនដំណឹង**

**ស្តីពី**

**ការបែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ២០២១**
**ដែលត្រូវបានស្នើឡើងក្នុងអំឡុងពេលកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកលើកទី១**
**របស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក**

**ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតទាំងអស់របស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មេត្តាជ្រាបថា ក្រុមហ៊ុននឹងធ្វើការបែងចែកភាគលាភជូនភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតសម្រាប់ឆ្នាំ២០២១ ដែលត្រូវបានស្នើឡើងក្នុងអំឡុងពេលកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិករបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ តាមការកំណត់ដូចខាងក្រោម:

| | | |
|---|---|---|
| ១. ប្រភេទភាគលាភដែលបានបែងចែក | : | ជាសាច់ប្រាក់ |
| ២. រយៈពេលភាគលាភ | : | ប្រចាំឆ្នាំ២០២១ |
| ៣. អនុបាតនៃការបែងចែកភាគលាភ | : | ៤៥,៨៨% |
| ៤. ភាគលាភសរុបដែលត្រូវបែងចែក | : | ៨៤៦.៤៦១.៤៧៨ រៀល |
| ៥. ភាគលាភក្នុងមួយ ឯកតាមូលបត្រកម្មសិទ្ធិ | : | ១៣១ រៀល |
| ៦. កាលបរិច្ឆេទកំណត់ទុក | : | ១៤ មិថុនា ២០២២ |
| ៧. កាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភពី | : | ២៣ មិថុនា ២០២២ ដល់ ០១ កក្កដា ២០២២ |

<u>បញ្ជាក់ :</u>

១. សេចក្តីសម្រេចនេះនឹងត្រូវបានបញ្ជាក់ ឬអនុម័តក្នុងអំឡុងពេលកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិករបស់ក្រុមហ៊ុន។

២. ភាគហ៊ុនិកដែលមានសិទ្ធិទទួលបានភាគលាភ ជាភាគហ៊ុនិកដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះភាគហ៊ុនិកផ្លូវការដែលទទួលបានពីបញ្ជីភាគហ៊ុនិកបណ្តោះអាសន្នដែលបានរៀបចំឡើងនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ ២០២២។

៣. ភាគហ៊ុនិកដែលលក់មូលបត្រកម្មសិទ្ធិរបស់ខ្លួននៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២ នៅមានសិទ្ធិទទួលបានភាគលាភដដែល។

៤. ភាគហ៊ុនិកដែលទិញមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុននៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២ នឹងមិនមានសិទ្ធិទទួលបានភាគលាភ ដូចបានកំណត់ខាងលើ។

៥. ការទូទាត់ភាគលាភ ចាប់ផ្តើមពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ ដល់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២ នៅរៀងរាល់ថ្ងៃធ្វើការ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្ររបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដូចខាងក្រោម:

- លោក លីម អាន ប្រធានផ្នែកប្រតិបត្តិការ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់
  - ទូរស័ព្ទលេខ ៖ (៨៥៥) ១៥ ៦០០ ៧៤៣
  - អ៊ីម៉ែល ៖ lim.an@acledabank.com.kh
- លោក ហួត សុភី អនុប្រធានផ្នែកប្រតិបត្តិការ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់
  - ទូរស័ព្ទលេខ ៖ (៨៥៥) ១៥ ៩០០ ៥៣៨
  - អ៊ីម៉ែល ៖ huot.sophy@acledabank.com.kh
- លោកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ បុគ្គលិកផ្នែកប្រតិបត្តិការ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់
  - ទូរស័ព្ទ ៖ (៨៥៥) ៦១ ២៨៧ ៧៦៦
  - អ៊ីម៉ែល ៖ op.rtp@acledabank.com.kh

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២

**ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក DBD ENGINEERING Plc. KINGDOM OF CAMBODIA